ធ៧-០២-២១៨ ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តប្លង់គណនីសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

**ប្រការ ១.-**

ដាក់ចេញប្លង់គណនី និងកាតព្វកិច្ចបើកចំហព័ត៌មានសម្រាប់គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែល បានទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជាឱ្យអនុវត្តដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ។

**ប្រការ ២.-**

ការអនុវត្តន៍នូវប្លង់គណនីនិងកាតព្វកិច្ចបើកចំហព័ត៌មានត្រូវចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៣។

**ប្រការ ៣.-**

របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងៗ រួមមានរបាយការណ៍រូបិយវត្ថុដែលត្រូវផ្ញើមក ធនាគារជាតិនៃកម្ពុជា សម្រាប់ខែមករា ឆ្នាំ២០០៣ និងគ្រាបន្តបន្ទាប់ត្រូវបំពេញត្រឹមត្រូវលើមូលដ្ឋានប្លង់គណនី និងកាតព្វកិច្ចបើកចំហព័ត៌មាន។

**ប្រការ ៤.-**

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិបង្កើតបន្ថែម ឬលុបចោលឈ្មោះ និងលេខគណនីតាមការចាំបាច់។

**ប្រការ ៥.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវអនុវត្តតាមផងដែរនូវស្តង់ដារគណនេយ្យកម្ពុជា ដែលចេញ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលកាតព្វកិច្ចគណនេយ្យកំណត់ដោយធនាគារជាតិនៃកម្ពុជា មានភាពខុសគ្នាពីស្តង់ដារ គណនេយ្យកម្ពុជា កាតព្វកិច្ចដែលតម្រូវដោយធនាគារជាតិនៃកម្ពុជាត្រូវមានប្រសិទ្ធភាពអនុវត្ត។

**ប្រការ ៦.-**

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្ត ម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**